Declassified to Public
19 December 2018

E378/8/4

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 31 / 05 / 2018
ម៉ោង (Time/Heure) : 15 : 35
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សម្ងាត់ / Confidential / Confidentiel

ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៨

ជូនចំពោះ៖ ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ពី៖ ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន៖ លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង
លោក Victor Koppe សហមេធាវីអន្តរជាតិការពារក្តី នួន ជា
ភាគីទាំងអស់ក្នុងសំណុំរឿង ០០២
លោក Isaac Endeley ប្រធានអង្គភាពគាំពារការការពារក្តី

កម្មវត្ថុ៖ អំពីឋានៈរបស់សហមេធាវីអន្តរជាតិការពារក្តី នួន ជា ក្នុងសំណុំរឿង ០០២/០២

១. អង្គជំនុំជម្រះសាលាដំបូងសូមធ្វើការកត់សម្គាល់ថា មាត្រា ៥ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាតម្រូវឲ្យមេធាវីបរទេសដែលប្រកបវិជ្ជាជីវៈនៅចំពោះមុខ អ.វ.ត.ក. ចុះឈ្មោះជាសមាជិកនៃគណៈមេធាវីបរទេសណាមួយ។ អង្គជំនុំជម្រះសាលាដំបូងបានទទួលដំណឹងថា លោក Victor Koppe ដែលជាសហមេធាវីអន្តរជាតិការពារក្តី នួន ជា ពុំមែនជាសមាជិកគណៈមេធាវីទីក្រុងអាំស្ទែរដាំ ឬ គណៈមេធាវីបរទេសណាមួយទេ ចាប់តាំងពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ មក។ លោក Victor Koppe បានអះអាងថា ថ្វីត្បិតតែយ៉ាងនេះក្តី គាត់ធ្លាប់បានបំពេញទៅតាមលក្ខខណ្ឌតម្រូវទាំងអស់រួចហើយ ហើយគាត់នៅតែជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានៅឡើយ។

២. ទាក់ទិននឹងចំណុចនេះ អង្គជំនុំជម្រះសាលាដំបូងស្នើសុំការបញ្ជាក់បំភ្លឺពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នូវចំណុចនានាដូចខាងក្រោម៖

ក. បន្ទាប់ពីចុះឈ្មោះនៅក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជារួចហើយ តើមេធាវីបរទេសដែលប្រកបវិជ្ជាជីវៈនៅចំពោះមុខ អ.វ.ត.ក. ចាំបាច់ត្រូវស្ថិតនៅជាសមាជិកគណៈមេធាវីបរទេសជាបន្តទៀតដែរ ឬ យ៉ាងណា?

ខ. ប្រសិនបើមេធាវីបរទេសដែលប្រកបវិជ្ជាជីវៈនៅចំពោះមុខ អ.វ.ត.ក. លែងជាសមាជិកគណៈមេធាវីបរទេសណាមួយ តើចំណុចនេះមានផលប៉ះពាល់អ្វីដែរ ឬ ទេ ដល់ការចុះឈ្មោះរបស់មេធាវីបរទេសនោះនៅក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា?

គ. លោក Victor Koppe ពុំមែនជាសមាជិកគណៈមេធាវីបរទេសណាមួយទេចាប់តាំងពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ មក តើការចុះឈ្មោះរបស់គាត់នៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានៅមានសុពលភាពដែរ ឬ ទេ ?

ឃ. ប្រសិនបើការចុះឈ្មោះរបស់គាត់នៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាលែងមានសុពលភាព តើគាត់ចាំបាច់ត្រូវធ្វើអ្វីខ្លះ ដើម្បីកែតម្រូវស្ថានភាពនេះ?

៣. អង្គជំនុំជម្រះសង្ឃឹមយ៉ាងមុតមាំថានឹងអាចទទួលបានការឆ្លើយតបពីគណៈមេធាវីចំពោះបញ្ហាទាំងនេះឆាប់តាមដែលអាចធ្វើទៅបាន និងយ៉ាងយូរបំផុតសុំឲ្យបានមុនថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៨។